# សមិទ្ធផលសេដាក ១២ ឆ្នាំ និងផែនការ ៥ ឆ្នាំខាងមុខ

នៅថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៩ សេដាក បានប្រារព្ធពិធីកិច្ចប្រជុំពេញអង្គលើកទី ១២ ក៏ដូចជាខួប ១២ ឆ្នាំរបស់ខ្លួនស្តីអំពី សមិទ្ធផលសេដាក ១២ ឆ្នាំ និងផែនការ ៥ ឆ្នាំខាងមុខ នៅវិទ្យាស្ថានជាតិអប់រំ ក្រុងភ្នំពេញ។ បុគ្គលិកចំនួន ១៨០ នាក់ (ស្ត្រី ៥៤ នាក់) បានចូលរួមក្នុងអង្គប្រជុំនេះ។ គោលបំនងនៃអង្គប្រជុំនេះគឺដើម្បីឆ្លុះបញ្ចាំងពីឥទ្ធិពលទៅលើសង្គម និងការវិវឌ្ឍន៍ ផ្ទាល់ខ្លួនក្នុងពេលធ្វើការងារជាមួយ សេដាក និងបង្ហាញអំពីទិដ្ឋភាពរួមនៃផែនកា សេដាក ឆ្នាំ ២០១៤។

បន្ទាប់ពីបញ្ជាក់ប្រាប់អំពីគោលបំណងនៃអង្គប្រជុំ និងប្រវត្តិរបស់អង្គការ សេដាក លោកបណ្ឌិត **យ៉ង សាំងកុមារ** បានលើកឡើងនូវសមិទ្ធផលសំខាន់ៗដែល សេដាក បានបំពេញបេសកកម្ម សង្គមបានជាច្រើន ក្នុងរយៈពេល ១២ ឆ្នាំកន្លងមក។ បេសកកម្មទាំងនោះមានដូចជា:

១- កសិករចំនួន **១ សែនគ្រួសារ** មកពី **៣២០០ ភូមិ**បានទទួលផលប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ សេដាក ដែលក្នុងនោះមានកសិករចំនួនជាង ៨០០០ គ្រួសារ បានបង្កើនទិន្នផលស្រូវតាមរយៈការអនុវត្តន៍ប្រព័ន្ធប្រពល-វប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស)

២- កសិករចំនួន ៧៧០០០ នាក់ បានចូលជាសមាជិកក្រុមសន្សំ ដែលមានចំនួនប្រមាណ ៥០០០ ក្រុម និងបានសន្សំប្រាក់បានចំនួន ១០.០០០ លានរៀល (ប្រមាណ ២,៥ លានដុល្លារអាមេរិក)

៣- មានកុមារចំនួន ២៤៩៨ នាក់ មកពី ៣៨៦ ភូមិ ដែលជាកូនរបស់គ្រួសារក្រីក្របំផុត បានចូលរៀនទៀងទាត់តាមរយៈការគាំទ្រពី សេដាក

៤- យុវជនជនបទចំនួន ៤០០ នាក់ បានទទួលឱកាសចូលរៀនពីជំនាញសហគ្រាសកសិកម្ម និងអភិវឌ្ឍន៍សហគមន៍

៥- យើងបានធ្វើការបោះពុម្ពផ្សាយនូវឯកសារសម្រាប់ផ្សព្វផ្សាយកសិកម្ម ជាពិសេសទស្សនាវដ្តីកសិករបានចំនួន ១២៧ លេខ

៦- សហការគាំទ្រដល់ក្រុមប្រឹក្សាឃុំចំនួន ៨៧ ឃុំ នៅក្នុង ៣ ខេត្តក្នុងការកែលម្អអភិបាលកិច្ចមូលដ្ឋាន

៧- គាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ (PLAHs) ចំនួន ៣០៧ នាក់ក្នុងការបង្កើននូវគុណភាពជីវិត

៨- ទទួលទស្សនកិច្ចសិក្សា និងការស្នាក់នៅរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសេដាក ទាំងក្នុង និងក្រៅប្រទេស បានចំនួនជាង ៨០០០ នាក់។

៩- ការផ្សារភ្ជាប់កសិករមកកាន់ទីផ្សារ

បន្ទាប់មក លោកបណ្ឌិត **យ៉ង សាំងកុមារ** បានលើកឡើងអំពីទិដ្ឋភាពរួមនៃផែនការ សេដាក ឆ្នាំ ២០១៤ ដែល សេដាក នឹងធ្វើការលើផ្នែក និងកម្មវិធីសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម:

១- ជម្រុញការផ្សព្វផ្សាយកសិកម្ម

២- ជំនួញសហគមន៍

៣- ការផ្សារភ្ជាប់កសិករមកកាន់ទីផ្សារ

៤- អភិបាលកិច្ចមូលដ្ឋាន

៥- កុមារកូនកសិករក្រីក្រ

៦- យុវជនជនបទ

៧- សហគ្រាស សេដាក ដើម្បីអភិវឌ្ឍន៍សង្គម

៨- ធនាគារ សេដាក

៩- សេវាកម្មបញ្ជាក់គុណភាពផលិតផល

១០-ការងារបោះពុម្ពផ្សាយ

១១-បណ្តាញអ្នកផ្តល់សេវាកម្មតាមសហគមន៍

១២-ប្រព័ន្ធធារាសាស្ត្រ

១៣-ស្រាវជ្រាវដើម្បីការអភិវឌ្ឍន៍

១៤-សេវាកម្មបណ្តុះបណ្តាល និងស្នាក់នៅរៀនសូត្រ

១៥-ការងារស្ត្រី-បណ្តាញស្ត្រីជនបទ

១៦-ឡជីវឧស្ម័ន

១៧-ឱសថបុរាណ

១៨-ការប្រែប្រួលអាកាសធាតុ

១៩-កសិដ្ឋាន សេដាក

២០- វេទិកាគ្រូបង្រៀន

២១-ទេសចរណ៍កសិកម្ម

២២-ការផ្សារភ្ជាប់វត្តអារាម និងការអភិវឌ្ឍន៍

២៣-ការងារគាំទ្របណ្តាញកសិករ និងធម្មជាតិ

២៤- អាជីវកម្មកៅស៊ូជាលក្ខណៈគ្រួសារ

២៥- ការងារអេតចាយ